រាជបណ្ឌិត្យសភាកម្ពុជា

# កវីប្រជាជនខ្មែរសម័យអាណាព្យាបាលបារាំង

# Khmer Popular Poets in France Protectorate Period

ចាន់ សុភា

និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ

ជំនាញ៖ អក្សរសិល្ប៍

ភ្នំពេញ ២០១៩

រាជបណ្ឌិត្យសភាកម្ពុជា

# កវីប្រជាជនខ្មែរសម័យអាណាព្យាបាលបារាំង

# Khmer Popular Poets in France Protectorate Period

បេក្ខជនបណ្ឌិត ៖ ចាន់ សុភា

និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ

ជំនាញ ៖ អក្សរសិល្ប៍

២០១៩

# មាតិកា


ឧទ្ទិសកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ ii

អំណះអំណាង ........ iii

ពាក្យប្រើជាអក្សរកាត់ ........ IV

មូលន័យសង្ខេប ........ v

មូលន័យសង្ខេបជាភាសាអង់គ្លេស ........ vii

សង្ខេបនិក្ខេបបទ ........ viii

សង្ខេបនិក្ខេបបទជាភាសាអង់គ្លេស ........ xx

អារម្ភកថា ........ xxviii


## សេចក្តីផ្តើម


១-លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២-ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៤

៣-គោលបំណងនៃការស្រាវជ្រាវ ........ ៥

៤-ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ........ ៥

៥-វិធីសាស្ត្រស្រាវជ្រាវ ........ ៦

៦-សារប្រយោជន៍នៃការស្រាវជ្រាវ ........ ៧

៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៨


## ជំពូក១

## ទស្សនៈទូទៅអំពីកវីក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ


១.១-ទស្សនៈទូទៅអំពីកវី ........ ៩

១.១.១-នរណាជាកវី? ........ ៩

១.១.២-តួនាទីរបស់កវី ........ ១២

១.១.៣-ប្រភេទនៃស្នាដៃរបស់កវី ........ ១៩

១.២-កវីខ្មែរតាមដំណាក់កាលប្រវត្តិសាស្ត្រ ........ ២៨

១.២.១-កវីខ្មែរសម័យមុនអង្គរ ........ ២៨

១.២.២-កវីខ្មែរសម័យអង្គរ ........ ៣០

១.២.៣-កវីខ្មែរសម័យក្រោយអង្គរ ........ ៣៤
១.៣-សង្គមប្រវត្តិនៃសម័យអាណាព្យាបាលបារាំង
១.៣.១-សម័យអាណាព្យាបាលបារាំង. ........ ៣៦
១.៣.២-តួនាទីវត្តអារាមក្នុងសង្គមខ្មែរ ........ ៣៨
១.៣.៣-ច្បាប់អប់រំបែបប្រពៃណី ........ ៤០
១.៣.៤-ប្រវត្តិនៃការរៀបចំចងក្រងលើស្លឹករឹត ........ ៤៣
១.៤-ការវាយតម្លៃរបស់អ្នកសិក្សាជាតិអំពី«កវីខ្មែរ» ........ ៤៧
១.៤.១-ការសិក្សារបស់លោក លាង ហាប់អាន អំពី «ព្រះរាជសម្ភារ» ........ ៤៧
១.៤.២-ការសិក្សារបស់លោក ឃីង ហុកឌី អំពី «ក្រមង៉ុយនិងស្នាដៃ» ........ ៥៩
១.៤.៣-ការសិក្សារបស់លោក សោម សុមុនី អំពី "តថភាពតាមរយៈច្បាប់ល្បើកថ្មី" ...
........ ៥០

## ជំពូក២

## និន្នាការអក្សរសិល្ប៍ខ្មែរក្នុងឆ្នាំ១៨៦៣-១៩៥៣

២.១-ស្ថានភាពសង្គម-វប្បធម៌ខ្មែរ ........ ៦៥
២.១.១-ទិដ្ឋភាពប្រវត្តិសាស្ត្រ ........ ៦៥
២.១.២-គុណវិបត្តិនៃការគ្រប់គ្រងរបស់បារាំង ........ ៧០
២.១.៣-សមិទ្ធផលសង្គមវប្បធម៌ដែលបារាំងបានកសាង ........ ៧៣
២.២-លក្ខណៈពិសេសនៃអក្សរសិល្ប៍ ........ ៧៥
២.២.១-អក្សរសិល្ប៍ប្រពៃណី(អក្សរសិល្ប៍ពុទ្ធនិយម) ........ ៧៥
២.២.២-អក្សរសិល្ប៍ឧបទេស ........ ៧៩
២.២.៣-អក្សរសិល្ប៍ប្រជាជន(អក្សរសិល្ប៍ប្រជាប្រិយ) ........ ៨៨
២.៣-កវីនិងស្នាដៃសំខាន់ៗ ........ ៩០
២.៣.១-សុត្តន្តប្រិយជាតិន្ទ ........ ៩០
២.៣.២-សន្ធរម៉ុក ........ ៩៦
២.៣.៣-អ្នកព្រះភិរម្យភាសាអ៊ូ ហៅង៉ុយ ........ ១១០
២.៣.៤-បណ្ឌិត ម៉ឺន ម៉ៃ ........ ១១៥

## ជំពូក៣

## គុណតម្លៃកវីប្រជាជនខ្មែរក្នុងសម័យអាណាព្យាបាលបារាំង

៣.១-ទស្សនៈអប់រំក្នុងជីវភាពរស់នៅ ........ ១២១
៣.១.១-អប់រំប្រជាជន ........ ១២១
៣.១.២-អប់រំមន្ត្រី ........ ១២៦
៣.១.៣-អប់រំព្រះសង្ឃ ........ ១២៨
៣.១.៤-អប់រំព្រះមហាក្សត្រ ........ ១៣០
៣.២-ការបណ្ដុះស្មារតីតស៊ូប្រឆាំងតាមបែបមនសិការជាតិ ........ ១៣១
៣.២.១-បណ្ដុះស្មារតីឯករាជម្ចាស់ការ ........ ១៣១
៣.២.២-បណ្ដុះស្មារតីសាមគ្គីក្នុងរង្វង់ប្រជាជាតិ ........ ១៣៣
៣.២.៣-បណ្ដុះស្មារតីឈឺចាប់ប្រឆាំងបារាំង ........ ១៣៤
៣.៣-ឥទ្ធិពលនៃកវីប្រជាជនខ្មែរមកលើសង្គមខ្មែរបច្ចុប្បន្ន ........ ១៣៥
៣.៣.១-ស្នាដៃរបស់កវីប្រជាជនខ្មែរក្លាយជាគំរូសម្រាប់ការតែងនិពន្ធ ........ ១៣៥
៣.៣.២-កិត្យានុភាពកវីប្រជាជនខ្មែរក្នុងស្មារតីជាតិ ........ ១៣៦
៣.៣.៣-តម្លៃអត្តសញ្ញាណជាតិក្នុងព្រលឹងខ្មែរ ........ ១៣៨
**សេចក្ដីសន្និដ្ឋាន** ........ ១៤០
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# មូលន័យសង្ខេប

សង្គមខ្មែរនាឆ្នាំ១៨៦៣ ដល់ ឆ្នាំ១៩៥៣ នេះ គឺស្ថិតនៅក្នុងរបបអាណាព្យាបាលបារាំង ដែលប្រជាជនខ្មែរកាលនោះមានការលំបាកខ្លាំង ណាមួយត្រូវបង់ពន្ធដារឱ្យបារាំងយកទៅបម្រើមហិច្ឆតានៃការធ្វើសង្គ្រាមរបស់ខ្លួន និងការស្តារសេដ្ឋកិច្ចរបស់បារាំងផង ម្យ៉ាងគឺត្រូវបង់ពន្ធសម្រាប់ស្តេចខ្មែរទៀត ធ្វើឱ្យប្រជាជនខ្មែរមួយភាគធំក្លាយជាអ្នកអវិជ្ជា មិនចេះអក្សរសាស្ត្រជាតិ ឯសាលារៀនក៏មិនមានការបើកទូលាយ ការបោះពុម្ពចងក្រងចំណេះដឹងក៏មិនត្រូវបានអនុញ្ញាត អ្នកចេះដឹងមានចំនួនត្រឹមតែបម្រើការឱ្យរដ្ឋបាលបារាំង។ កាលនោះយើងឃើញថាវត្តអារាមនិងព្រះសង្ឃ ដើរតួនាទីសំខាន់ក្នុងការជួយជ្រោមជ្រែងក្នុងការអប់រំយុវជនខ្មែរឱ្យមានសីលធម៌ មានការចេះដឹងអក្សរសាស្ត្រជាតិ ស្គាល់ពីប្រពៃណី ទំនៀមទម្លាប់ជាតិ មានការអប់រំណែនាំពីកវីដែលមានចំណេះដឹងពីការបួសរៀនតាមរយៈវត្តអារាម ព្រះពុទ្ធសាសនាមកទូន្មានប្រៀនប្រដៅ ឱ្យមើលឃើញពីការជិះជាន់និងកេងប្រវ័ញ្ចពីពួកបារាំងនិងស័ក្តិភូមិ និងចេះកសាងជីវភាពរស់នៅឱ្យសមរម្យ និងកុំឱ្យបរទេសមកនៅស្រុកខ្មែរ ហើយធ្វើម្ចាស់លើខ្មែរទៀត។

ការសិក្សាស្រាវជ្រាវប្រធានបទ "កវីប្រជាជនខ្មែរសម័យអាណាព្យាបាលបារាំង" នេះ ចង់ឱ្យកូនខ្មែរមើលឃើញពីវីរភាពរបស់កវីប្រជាជនខ្មែរ ដែលមានកំណើតពីប្រជាជនរស់នៅជាមួយប្រជាជន និងធ្វើអ្វីៗដើម្បីប្រជាជន ជាពិសេសគឺពេលដែលប្រទេសជាតិនិងប្រជាជនមានទុក្ខលំបាក គឺវីរកវីយើងបានចេញមុខជួយអប់រំ និងបណ្តុះស្មារតីស្នេហាជាតិធ្វើឱ្យជាតិមានសាមគ្គីភាពអាចតស៊ូប្រឆាំងនិងពួកឈ្លានពានជិះជាន់នឹងទទួលបានជោគជ័យ។ ចំពោះតម្លៃអក្សរសិល្ប៍នៅក្នុងស្នាដៃរបស់ពួកគាត់ គឺការប្រើប្រាស់ទេពកោសល្យនៃការតែងនិពន្ធការចាប់ចុងចួន ការប្រើពាក្យពេចន៍ដែលជាភាសារបស់អ្នកស្រុក គឺសុទ្ធតែមានតម្លៃមិនអាចកាត់ថ្លៃបានទេ ក្នុងសង្គមអ្នកអក្សរសិល្ប៍ និងចំណេះដឹងអក្សរសិល្ប៍ដោយការលើយកបញ្ហាក្នុងសង្គមមនុស្សមកចោទនិងដោះស្រាយ ហើយបានផ្សារភ្ជាប់នឹងជីវភាពសង្គមទៀតផង ដូចជាការរកស៊ីចិញ្ចឹមជីវិត ការជ្រើសរើសគូស្រករ ការបម្រើការងារជាមន្ត្រីរាជការ ការទូន្មានដល់បុព្វជិត និងព្រះមហាក្សត្រជាដើម។

ឥទ្ធិពលរបស់កវីប្រជាជន ពិតជាតម្រូវឱ្យសង្គមបច្ចុប្បន្នយកមកសិក្សា និងផ្តល់ដល់យុវជនជំនាន់ក្រោយមើលឃើញពីគុណតម្លៃទាំងនេះ ដូចជាសីលធម៌សង្គម ការឱ្យតម្លៃវាំងមនុស្សចាស់ និងការជួយឱ្យអ្នកជំនាន់ក្រោយខ្លាំងលើចំណេះដឹង មានសីលធម៌ សុជីវធម៌ដើម្បីក្លាយជាធនធានដែលជាមនុស្សពេញលេញ អាចកសាងប្រទេសឱ្យមានការអភិវឌ្ឍរីកចម្រើនជឿនលឿន ដូចប្រទេសដទៃលើពិភពលោកនាពេលអនាគត។

## Abstract

The Khmer society from ១៨៦៣to ១៩៥៣was under the French guardianship, at that time the Khmer people encountered tremendous difficulties including paying taxes to the French administration as to serve French's war ambition and to restore French economy. On the other hand, it is necessary to pay taxes for the Khmer king and it makes the majority of Cambodians become illiterate, while schooling was not openly operational. Book publication, and compilation of knowledge were not allowed. As for number of educated people were only those who worked for the French administration.

At that time, pagodas and monks played an important role in helping educate Cambodian youths to be morally knowledgeable, to have insights into Khmer national literature, traditional customs, and to be knowledgeable about well-educated poets in Buddhist monasteries who advise young generation to see oppression and exploitation of the French administration and feudalists, and to make a decent living condition so as not for foreigners who lived in the country, to look down on or mistreat us, to be our master.

The study on "Khmer Popular Poets of the French guardianship period" wants to make Khmer young people see the epic of Cambodian poets who were born of people living with the people and doing things for the people, especially when the country and people were in trouble, our hero have come to help educate and cultivate the spirit of patriotism, national solidarity, and make a nation can unite against the oppressors and invaders successfully.

For the literary value, our poets and authors were talented at writing poetical and literary masterpieces by using language of local people and their literary works are priceless in society, literature and literary knowledge. Problem solving in society was questioned and addressed and linked to social life such as livelihood, couple options, civil servants, as well as instruction to pontiff (Buddhist monk) and the monarch.

The influence of popular poets really requires the present society to study and provide to the younger generation these values, such as social morality, value and respect for the elderly, and to empower the younger generation to be knowledgeable, moral, and ethical so as to become a full-fledged resource that can build a prosperous country like other countries all over the world in the future.

Therefore, major studies of some masterpieces and the practical studies of Cambodian poets are very important for literary writers because it helps to understand the value of literature and the development of this sector more deeply in the future.